ទី

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៥-១២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៣៨ ស្តីពីការតែងតាំង :
១-ឯកឧត្តម **ព្រហ្ម ញាណទិចិត្រ** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី
២-ឯកឧត្តម **រាយ គីម** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ៣៤៦២

០៧-១២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៣៩ ស្តីពីការដាក់ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ នូវមន្ត្រីថ្នាក់ដឹកនាំ ចំនួន ០៦ រូប ៣៤៦៣

១០-១២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៤០ ស្តីពីការអនុញ្ញាតឱ្យឯកឧត្តម **ហោ ម្វូ** លាឈប់ពីមុខតំណែងអនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទៅទទួលមុខតំណែងថ្មី ៣៤៦៥

១០-១២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៤១ ស្តីពីការ ប្រោសព្រះរាជទាន ចំពោះឯកឧត្តម **ញឹម វណ្ណដា** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ៣៤៦៦

១២-១២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៤២ ស្តីពីការតែងតាំងឯកឧត្តម **គង់ ឫទ្ធី** ជាឧបការីសម្តេច **ហេង សំរិន** អនុប្រធានទី ១ រដ្ឋសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៣៤៦៧

១៣-១២-២០០២ -ព្រះរាជក្រឹត្យ នស/រកត/១២០២/៣៤៣ ស្តីពីការបញ្ចប់តំណែងជាទីប្រឹក្សាអមឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២ ចំនួន ០២ រូប ៣៤៦៨

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៦-១២-២០០២ -អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្តីពី ការទទួលស្គាល់សាកលវិទ្យាល័យអន្តរជាតិ ៣៤៦៩

១៦-១២-២០០២ -អនុក្រឹត្យលេខ ១២៣ អនក្រ.បក ស្តីពីការកែសម្រួលខ្លឹមសារអនុក្រឹត្យលេខ៤១អ.ន.ក្រ បក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ៣៤៧២

២០-១២-២០០២ -អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពីការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ៣៤៧៤

<u>***បញ្ជាក់***</u> -(អនុក្រឹត្យលេខ ១២៥ អនក្រ.បក) ***គ្មាន***

២៣-១២-២០០២ -អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានស្ថិតិ និង ពត៌មាន ចំណុះអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម ៣៤៧៦

១៦-១២-២០០២	-អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្ដីពីការជូន មេដាយស្ថាបនាជាតិ	៣៤៧៩
១៦-១២-២០០២	-អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្ដីពីការជូន មេដាយស្ថាបនាជាតិ	៣៤៨០
១៦-១២-២០០២	-អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្ដីពីការជូន មេដាយសហមេត្រី	៣៤៨១
១៦-១២-២០០២	-អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្ដីពីការជូន មេដាយស្ថាបនាជាតិ	៣៤៨២
១៦-១២-២០០២	-អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្ដីពីការអនុវត្តវិន័យនាយនគរបាលជាតិ	៣៤៨៣
១៦-១២-២០០២	-អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់	៣៤៨៤
១៧-១២-២០០២	-អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្ដីពីការជូន មេដាយការងារ	៣៤៨៥
១៧-១២-២០០២	-អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្ដីពីការជូន មេដាយការងារ	៣៤៩៥
១៧-១២-២០០២	-អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្ដីពីការជូន មេដាយការងារ	៣៤៩៦
១៧-១២-២០០២	-អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្ដីពីការជូន មេដាយការងារ	៣៤៩៨
១៧-១២-២០០២	-អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្ដីពីការជូន មេដាយការងារ	៣៥០០
១៧-១២-២០០២	-អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្ដីពីការជូន មេដាយស្ថាបនាជាតិ	៣៥០២
១៧-១២-២០០២	-អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្ដីពីការអនុញ្ញាតឱ្យមន្ត្រីរាជការផ្អាកការងារ ដោយគ្មានបៀវត្ស	៣៥០៣
១៨-១២-២០០២	-អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្ដីពីការជូន មេដាយស្ថាបនាជាតិ	៣៥០៤
១៨-១២-២០០២	-អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្ដីពីការជូន មេដាយស្ថាបនាជាតិ	៣៥០៥
២០-១២-២០០២	-អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្ដីពីការជូន មេដាយស្ថាបនាជាតិ	៣៥០៧
២៣-១២-២០០២	-អនុក្រឹត្យលេខ ៥៨១ អនក្រ.តត ស្ដីពីការជូន មេដាយមុនីសារាភ័ណ្ឌ	៣៥០៨
២៣-១២-២០០២	-អនុក្រឹត្យលេខ ៥៨២ អនក្រ.តត ស្ដីពីការជូន មេដាយសហមេត្រី	៣៥០៩

III-ការងារបណ្ដាក្រសួង

១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

០៩-១២-២០០២	-ប្រកាសលេខ ៣៣៧ សកបយ ស្ដីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល	៣៥១១

ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

១- ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- ឯកឧត្តម **នាយ គីម** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : *៧៥៩* ច.ល

៣រល.០៧.១២.០០៣៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០២

បានឃើញថាត្រឹមត្រូវចំលងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ាវ គាន

ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៣៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៩ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានដាក់ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌរដ្ឋបាលសាធារណៈ នូវមន្ត្រីថ្នាក់ដឹកនាំ ចំនួន ០៦រូប ដូចមាននាយនាមខាងក្រោម :

១- ឯកឧត្តម **វណ្ណ ម៉ូលីវណ្ណ** ទីប្រឹក្សារាជរដ្ឋាភិបាល និងជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

២- ឯកឧត្តម **ឃុន ឈើ** ទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី

៣- ឯកឧត្តម **ចាន់ តិន** សមាជិកព្រឹទ្ធសភា

៤- ឯកឧត្តម **អៀវ លីមស្រូវ** សមាជិករដ្ឋសភា

៥- ឯកឧត្តម **ហាវ ម៉ុនសែ** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី

៦- ឯកឧត្តម **ស ណារ៉ូត** ឧត្តមមន្ត្រីថ្នាក់លេខ ២

មាត្រា ២ : ចំពោះមន្ត្រីថ្នាក់ដឹកនាំ ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ដូចមានរាយនាមក្នុងមាត្រា ១ ខាងលើ នៅបន្តមុខដំណែងនយោបាយដដែល រហូតដល់មានការសំរេចជាថ្មី ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

៣រល.០២.១២.០០៣៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០២

លេខ : ២៥៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណារិទ្ធ តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានអនុញ្ញាតឱ្យឯកឧត្តម **ហេង ឬ** លាឈប់ពីមុខតំណែងអនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទៅទទួលមុខតំណែងថ្មី ។

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ២៥៤ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ឥន្ទ

ពរស.០៧.១៧.០០៣៦១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០២

ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៨១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម **ញឹម វណ្ណដា**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

ចរ.០៧.១៧.០០៣៦៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០០២

លេខ : ២៥៦ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៤២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ១០៤៥ រស ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម គង់ ឫទ្ធី ជាឧបការី សម្តេច ហេង សំរិន អនុប្រធានទី១រដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឱ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ ២៥៨ ច.ល

ដើម្បីចម្លងចែក

៣.ល.០២.១២.០០៣៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ទាន់

ព្រះរាជក្រឹត្យ

នស/រកត/១២០២/៣៤៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: បញ្ចប់តំណែងជាទីប្រឹក្សាអមឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី២ ចំនួន ០២រូប ដូចខាងក្រោម :

១- ឯកឧត្តម **សំរាំង កំសាន្ត**

២- ឯកឧត្តម **ថែម ឧត្តរិការ**

មាត្រា ២: នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ :២៤៧ច.ល

ដើម្បីចម្លងចែក

៣កស.០៧.១២.០០៣៦៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុំ... ឌាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤២៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់សាកលវិទ្យាល័យអន្តរជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ .នស .៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក អ៊ួន សាបូ ចុះថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០២
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

សំរេច

មាត្រា ១ : ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "សាកលវិទ្យាល័យអន្តរជាតិ" " INTERNATIONAL UNIVERSITY " ហៅកាត់ជាភាសាខ្មែរ "ស.អ" និង ហៅកាត់ជាភាសាអង់គ្លេស "I.U" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួង អប់រំ យុវជន និង កីឡា និងមានទីតាំងគោលស្ថិតនៅអាគារលេខ ៣៥, ៣៧, ៣៩, ៤១ ផ្លូវលេខ ៥៨២ សង្កាត់ បឹងកក់ ២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យអន្តរជាតិធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត ជាមធ្យម ។
- ថ្នាក់គិលានុបដ្ឋាកមធ្យម ឆ្មបមធ្យម ឱសថការីមធ្យម សិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ ។
- ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត ជាមធ្យម ។

- ថ្នាក់វេជ្ជបណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៦ឆ្នាំ ។
- ថ្នាក់ទន្តបណ្ឌិត សិក្សារយៈពេលយ៉ាងតិច ៥ឆ្នាំ ។
- ថ្នាក់ឱសថការីឧត្តម សិក្សារយៈពេលយ៉ាងតិច ៥ឆ្នាំ ។
- ថ្នាក់ម៉ាស្ទ័រ សិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីត ជាមធ្យម ។
- ថ្នាក់វេជ្ជបណ្ឌិតឯកទេស ទន្តបណ្ឌិតឯកទេស ឱសថការីឯកទេស ដែលមានកំរិតស្មើនឹង ថ្នាក់ម៉ាស្ទ័រត្រូវសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ បន្ទាប់ពីបានសញ្ញាប័ត្រវេជ្ជបណ្ឌិត ទន្តបណ្ឌិត និង ឱសថការីឧត្តម ឬ បរិញ្ញាប័ត្រឱសថការី ។
- ថ្នាក់បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេលយ៉ាងតិច ៣ឆ្នាំ ។

មាត្រា ៣ : សាកលវិទ្យាល័យអន្តរជាតិមាន :

១- មហាវិទ្យាល័យ បច្ចេកវិទ្យា និង វិទ្យាសាស្ត្រ
២- មហាវិទ្យាល័យ មនុស្សសាស្ត្រ និង ភាសា
៣- មហាវិទ្យាល័យ វិទ្យាសាស្ត្រសង្គម និង សារព័តមាន
៤- មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
៥- មហាវិទ្យាល័យ នីតិសាស្ត្រ
៦- មហាវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម និង អភិវឌ្ឍន៍ជនបទ
៧- មហាវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ឬ កំរិត ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យអន្តរជាតិ មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យ និង សំរេច លើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ ហើយមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ សំរាប់ពិនិត្យ និង ផ្តល់យោបល់លើ កម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៥ : លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុត បានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនដែលមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជនដែលមានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រដែលមានតំលៃស្មើ ។
- ចំពោះការចូលរៀននៅក្នុងមហាវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីលក្ខខ័ណ្ឌនៃការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

មាត្រា ៦ : សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអន្តរជាតិមានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើស សិស្ស-និស្សិត អោយចូលរៀននិងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។

- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមកាលកំណត់ ។

មាត្រា ៧ : និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យអន្តរជាតិ និង ទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា ។ សញ្ញាប័ត្រនេះត្រូវបានផ្តល់អោយ ដោយសាកលវិទ្យាល័យអន្តរជាតិ ហើយត្រូវបានទទួលស្គាល់ពីក្រសួង អប់រំ យុវជន និង កីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បំពេញ និង អនុវត្តបានតាមគោលការណ៍កំនត់របស់ ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យអន្តរជាតិមានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្តនិងប្រតិបត្តិតាមអនុក្រឹត្យនេះ ។

មាត្រា ៩ : អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង អនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- សាលាក្រុងភ្នំពេញ
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១២៣ . អនក្រ. បក

អនុក្រឹត្យ

ស្តីពី

ការកែសំរួលខ្លឹមសារអនុក្រឹត្យលេខ ៤១ អ.ន.ក្រ បក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១.-

ត្រូវបានកែសំរួលខ្លឹមសារអនុក្រឹត្យលេខ ៤១អ.ន.ក្រ បក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ នៅត្រង់ឃ្លាចំណុចទី១ មាត្រា៤ នៃជំពូកទី៣ ក្នុងសមត្ថកិច្ច និងភារកិច្ចរបស់នាយកដ្ឋាននគរបាលស្តីតិនិងលិខិតឆ្លងដែន ដែលចែងថា : "គ្រប់គ្រងការចុះបញ្ជីមុខរបរពិសេស" ដកមកបញ្ចូលក្នុងចំណុចទី១ មាត្រា៥ នៃជំពូកទី៣ ដោយបន្តពីឃ្លាខាងដើមនៅក្នុងភារកិច្ចរបស់នាយកដ្ឋានគ្រប់គ្រងអាវុធ ជាតិផ្ទុះ និង អគ្គីភ័យវិញ ។

ឋ

មាត្រា២.–

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

សែន

កន្លែងទទួល

- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១២៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១/៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា១: ត្រូវបានបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំនួន ៦០០ កន្លែង (ប្រាំមួយរយកន្លែង) សំរាប់បង្កើតវរសេនាតូចនគរបាលការពារព្រំដែនគោកប្រចាំខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ។

មាត្រា២: ប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនគរបាលជាតិទាំងនេះ ត្រូវបានផ្តល់ជូនចាប់ពីខែ មិនា ឆ្នាំ ២០០៣ តទៅ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១២៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតនាយកដ្ឋានស្ថិតិ និងពត៌មាន
ចំណុះអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

មាត្រា ១ .-

ត្រូវបានបង្កើត នាយកដ្ឋានស្ថិតិ និងពត៌មាន ចំណុះអគ្គនាយកដ្ឋានបច្ចេកទេស នៃ ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ ._

នាយកដ្ឋានស្ថិតិ និងពត៌មាន មានភារកិច្ច ដូចតទៅ :

- ស្រាវជ្រាវ និងធ្វើស្ថិតិពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការលើវិស័យស្ថិតិពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- សិក្សា និង សហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំ អង្កេត ប្រមូល ចងក្រង និង វិភាគពត៌មានស្ថិតិពាណិជ្ជកម្ម
- ចងក្រង និង ណែនាំអនុវត្តដោយឯកភាព តាមចំណាត់ថ្នាក់ពត៌មានស្ថិតិពាណិជ្ជកម្ម និងបណ្តាតារាងគំរូ
- ផ្សព្វផ្សាយទិន្នន័យស្ថិតិពាណិជ្ជកម្ម ស្តីពីស្ថានភាពនៃការវិវត្តទីផ្សារផ្នែកពាណិជ្ជកម្ម ក្នុង និងក្រៅប្រទេស
- ស្រាវជ្រាវ វិភាគ ផ្សព្វផ្សាយការប្រែប្រួលថ្លៃទំនិញចរាចរក្នុងប្រទេស និងត្រួតពិនិត្យតាមដានទិន្នាការសន្ទស្សន៍ថ្លៃរបស់បណ្តាប្រទេសនានា
- សិក្សា ស្រាវជ្រាវ ប្រមូល និងវិភាគពត៌មានតាមលំដាប់ដើម្បីបង្កើតតារាង នៃការប្រែប្រួលថ្លៃ និងការប្រែប្រួលគុណភាព
- ប្រមូលយកពត៌មានអំពីថ្លៃទំនិញប្រើប្រាស់ និងសេវាកម្ម តាមកាលកំណត់ និងចងក្រងការប្រែប្រួលថ្លៃទំនិញប្រើប្រាស់ និងសេវាប្រចាំខែ ត្រីមាស ៩ខែ និងប្រចាំឆ្នាំ
- ធ្វើគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញស្ថិតិពាណិជ្ជកម្ម និងពត៌មានពាណិជ្ជកម្មពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋានតាមតំរូវការការងារ
- ទទួលបន្ទុកជា មជ្ឈមណ្ឌលពត៌មានពាណិជ្ជកម្ម របស់ក្រសួង
- គ្រប់គ្រង និងអភិវឌ្ឍន៍ពត៌មាន ប្រព័ន្ធទិន្នន័យសេដ្ឋកិច្ច ពាណិជ្ជកម្ម
- គ្រប់គ្រង និងអភិវឌ្ឍន៍បច្ចេកទេសពត៌មានវិទ្យា ។

មាត្រា ៣ ._

នាយកដ្ឋានស្ថិតិ និងពត៌មាន ដឹកនាំ ដោយប្រធានមួយរូប និងអមដោយអនុប្រធាន ជាជំនួយការ ។

មាត្រា ៤ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៦៥.អនក្រ-បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសំរឹទ្ធស្ថាបនាជាតិ** ជូន សមាគម ចំនួន ០៦ នៅប្រទេសជប៉ុន ដែលបានរួមគ្នាផ្តល់អំណោយជាថវិកា ចំនួន ២២.១១៣ USD សំរាប់កសាងអគារសិក្សា ០១ ខ្នង ដោយបំពាក់សម្ភារិមគ្រប់គ្រាន់ ជូនសាលាបឋមសិក្សាត្រមែង ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត ដូចមានរាយនាមខាងក្រោមនេះ ÷

១-សមាគម **VOLUNTEER KOBONOKIA**

២-សមាគម **KOUMYO TEMPLE**

៣-សមាគម **DAISHININ**

៤-សមាគម **ICHIKANJI SIENSYA ICHIDOU**

៥-សមាគម **ENTSUJI**

៦-សមាគម **HOUSYA KUJI**

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៥០៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍស្ថាបនាជាតិ** ជូនលោកវរសេនីយ៍ឯក **DON HIGGIN** សេនាទុតិយអមស្ថានទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើអំណោយជាថវិកាចំនួន ៤.៩៥០ ដុល្លារអាមេរិក សំរាប់ជួយកសាងនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងការពារជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច ✓

-ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦៧ អនក.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សរឫទ្ធិ** ជូនលោកវរសេនីយ៍ឯក T S Gill អនុព័ន្ធយោធាអមស្ថានទូត នៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញបេសកកម្មនៅកម្ពុជា រយៈពេល ០៣ ឆ្នាំ ប្រកបដោយស្នាដៃល្អ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៥៦៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនអង្គការ **លូធើរាន** បំរើពិភពលោក (L W F) ដែលបានផ្តល់ថវិកា ជួយកសាងអគារសិក្សា ០១ ខ្នង មានចំនួន ០៦ បន្ទប់ បំពាក់សំភារៈសិក្សាគ្រប់គ្រាន់ ធ្វើបង្គន់អនាម័យ ក្លោងទ្វារ របងលួសបន្លា ព័ទ្ធជុំវិញសាលារៀន និងសួនកូនឈើ នៅភូមិវាលស្បូវ ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចំណាយអស់ទឹកប្រាក់ចំនួន ៣២.៦៦៤ ដុល្លារអាមេរិក ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៨ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច ✓
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៦៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការអនុវត្តវិន័យនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា១ : ត្រូវបានអនុវត្តវិន័យចំពោះលោកវរៈសេនីយ៍ឯក **ខែ មង្គរី** អត្តលេខ ០១៤៩ ឋានៈ អនុប្រធាននាយកដ្ឋានពតិមានទូទៅ នៃក្រសួងមហាផ្ទៃ ដោយរូបភាពដកហូតតួនាទី ឋានន្តរសក្តិ និងបណ្តេញចេញពីក្របខ័ណ្ឌនគរបាលជាតិ មូលហេតុ : បានបោះបង់ចោលការងារ ។

មាត្រា២ : ប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗត្រូវបានកាត់ចេញពីក្របខ័ណ្ឌនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ចាប់ពីខែ.....ឧ........ឆ្នាំ ២០០២ នេះតទៅ ។

មាត្រា៣ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៦ ខែ ៨ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៧០ . អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/ ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា១ : ត្រូវបានតែងតាំងមុខតំណែងលោកវរៈសេនីយ៍ឯក **ហ៊ិន យក់លីម** អត្តលេខ ០៥០០ បច្ចុប្បន្នជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួង-មហាផ្ទៃ ។

មាត្រា២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ៥ ឆ្នាំ ២០០...

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

****

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសំរិទ្ធការងារ** ជូនមន្ត្រីរាជការចំនួន ២៤៨ រូប នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចឆ្នាំ ២០០១-២០០២ ដូចមាននាយនាមខាងក្រោមនេះ ÷

១-លោក	**ជា**	**ចាន់ថន**	អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
២-លោកស្រី	**ឈួន**	**ណារី**	ប្រធានការិ.ថវិកា នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៣-លោក	**ហាង**	**សោផល**	អនុប្រធានការិ.ថវិកា នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៤-លោក	**អ៊ឹម**	**រិត**	មន្ត្រីក្រមការ នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៥-លោក	**នាង**	**ញ៉ី**	លេខាធិការ នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៦-លោក	**យាន**	**សុវណ្ណារ៉ា**	ប្រធានការិ.អចលនកម្ម នៃនាយកដ្ឋានសំភារៈ និងបរិក្ខារ
៧-លោក	**អ៊ិន**	**ស៊ីថុល**	អនុប្រធានការិ.សំណង់វប្បធម៌ នៃនាយកដ្ឋានសំភារៈ និងបរិក្ខារ

៨-លោក	ទឹម	ទ៊ាន	អនុប្រធានការិ.សំភារៈ និងផ្គត់ផ្គង់	នៃនាយកដ្ឋានសំភារៈ និងបរិក្ខារ
៩-លោកស្រី	មុខ	ណាវិន	អនុប្រធានការិ.រដ្ឋបាល និងលទ្ធកម្ម	នៃនាយកដ្ឋានសំភារៈ និងបរិក្ខារ
១០-លោកស្រី	ទ៉ាន់	ចាន់នី	អនុប្រធានការិ.ផលិតឯកសារ និងផលិតផលវប្បធម៌	នៃនាយកដ្ឋានសំភារៈ និងបរិក្ខារ
១១-លោក	សុខ	វណ្ណី	អនុប្រធានការិ.រដ្ឋបាល	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១២-លោក	អោង	គឹមអ៊ីវ	អនុប្រធានការិ.បណ្តុះបណ្តាល	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១៣-លោក	កែវ	ឃ្លី	អនុប្រធានការិ.បច្ចេកទេស	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១៤-លោក	ឆេស	សំរុល	អនុការិ.ទស្សនីយភាពតន្ត្រីសម័យ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១៥-លោក	គ្រី	អូន	អនុការិ.បណ្តុះបណ្តាលល្ខោន	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១៦-លោក	នូ	ទ៉ាន់ឌី	អនុការិ.បណ្តុះបណ្តាលតន្ត្រីស្បែក	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១៧-លោក	នៅ	សុខរិន	អនុការិ.បច្ចេកទេស	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១៨-លោក	គួច	គីមឃន	អនុការិ.ទស្សនីយភាពស្បែក	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១៩-លោកស្រី	គីម	ម៉ឺនធំ	ប្រធានការិ.អធិការកិច្ចរបាំ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២០-លោកស្រី	ទ៉ី	ស៊ីវន	អនុការិ.ទស្សនីយភាពរបាំ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២១-លោក	អ៊ុំ	ឈឿត	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២២-លោក	យឹម	សែម	បុគ្គលិក រដ្ឋបាល	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៣-លោក	ម៉ុត	ចាន់ណា	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៤-លោកស្រី	ថោង	បូរ៉ាន់	អនុប្រធានការិយាល័យរដ្ឋបាល	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៥-លោកស្រី	អិម	ធារី	អនុប្រធានការិយាល័យ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៦-លោក	ឃី	សំណាង	តន្ត្រីករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៧-លោក	អេង	ឈាហេង	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៨-លោក	ម៉ៅ	ម៉ុណ្ណា	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៩-លោក	ពិន	សារឿន	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣០-លោក	ណុប	សម្បូរណា	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣១-លោកស្រី	ស៊ិន	សុវណ្ណារី	សិល្បការិនី	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣២-លោក	ហ៊ល	ចំរើន	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣៣-លោក	តង	ឈឿម	សិល្បករ	នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

៣៤-លោក	ថូ	ផុល	មន្ត្រីក្រុមការ នៃនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៣៥-លោក	ផៃ	ចាន់សុផល	មន្ត្រីក្រុមការ នៃនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៣៦-លោកស្រី	កែ	ចន្ថា	លេខាធិការ នៃនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៣៧-លោកស្រី	សាក់	ស្មូច	ភ្នាក់ងាររដ្ឋបាល នៃនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៣៨-លោកស្រី	ភង	សុផ្លារី	ភ្នាក់ងាររដ្ឋបាល នៃនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៣៩-លោក	អ៊ូ	សំរុល	ភ្នាក់ងាររដ្ឋបាល នៃនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៤០-លោកស្រី	ម៉ុំ	ស៊ីយ៉ុន	ភ្នាក់ងាររដ្ឋបាល នៃនាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៤១-លោកស្រី	សាន	សាវត្តី	បុគ្គលិកការិយាល័យរដ្ឋបាល នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤២-លោក	ធី	ទិត	បុគ្គលិកការិយាល័យរដ្ឋបាល នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤៣-លោក	មិត្ត	សេដ្ឋា	បុគ្គលិកការិ.សកម្មភាពវប្បធម៌ និងពិពណ៌ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤៤-លោក	ស្វាយ	ថន	អនុប្រធានការិ.វប្បធម៌ជនជាតិ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤៥-លោក	លី	វណ្ណថេន	អនុប្រធានការិ.សមាគម នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤៦-លោក	អ៊ុយ	ម៉េងចាយ	បុគ្គលិកការិ.សកម្មភាពវប្បធម៌ និងពិពណ៌ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤៧-លោក	នួ	សំរ៉េល	បុគ្គលិកការិ.សកម្មភាពវប្បធម៌ និងពិពណ៌ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤៨-លោក	សន	មាន	បុគ្គលិកការិ.សកម្មភាពវប្បធម៌ និងពិពណ៌ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌
៤៩-លោក	គ្រីន	សុខឡា	អនុប្រធានការិ.សិល្បៈសិប្បកម្ម នៃនាយកដ្ឋានសិល្បៈសូនរូប និងសិប្បកម្ម
៥០-លោកស្រី	ខៀប	ធាវិន	មន្ត្រីក្រុមការ នៃនាយកដ្ឋានសិល្បៈសូនរូប និងសិប្បកម្ម
៥១-លោក	ហៀង	ហេង	មន្ត្រីក្រុមការ នៃនាយកដ្ឋានសិល្បៈសូនរូប និងសិប្បកម្ម
៥២-លោក	ប៉ុក	ជុនណាត	មន្ត្រីក្រុមការ នៃនាយកដ្ឋានសិល្បៈសូនរូប និងសិប្បកម្ម
៥៣-លោក	កែវ	សំអាន	មន្ត្រីក្រុមការ នៃនាយកដ្ឋានសិល្បៈសូនរូប និងសិប្បកម្ម
៥៤-លោក	ម៉ៅ	ម៉ុន	មន្ត្រីក្រុមការ នៃនាយកដ្ឋានសិល្បៈសូនរូប និងសិប្បកម្ម
៥៥-លោក	លឹម	សុខ	អនុប្រធានការិយាល័យរដ្ឋបាល នៃសាលាបណ្ដុះបណ្ដាលក្របខ័ណ្ឌវប្បធម៌
៥៦-លោក	ថ្លាង	សាឃឿន	អនុប្រធានការិយាល័យអភិរក្ស នៃនាយកដ្ឋានសារៈមន្ទីរ
៥៧-លោក	នង	ផល	ប្រធានផ្នែករដ្ឋបាល នៃនាយកដ្ឋានសារៈមន្ទីរ
៥៨-លោក	កែប	សុវណ្ណ	ប្រធានក្រុមស្ដង់ នៃនាយកដ្ឋានសារៈមន្ទីរ
៥៩-លោក	ម៉ៅ	ទុធី	ប្រធានក្រុមមគ្គុទ្ទេសក៍ នៃនាយកដ្ឋានសារៈមន្ទីរ
៦០-លោក	ស្រី	វន	ប្រធានក្រុមជាង នៃនាយកដ្ឋានសារៈមន្ទីរ
៦១-លោក	ជឹម	ពឿន	អនុប្រធានក្រុមជាង នៃនាយកដ្ឋានសារៈមន្ទីរ

៦២-លោក	អ៊ុក	សារឿន	ប្រធានក្រុមសណ្ដាប់ធ្នាប់ នៃនាយកដ្ឋានសារៈមន្ទីរ
៦៣-លោក	គង់	សំណាង	ប្រធានក្រុមសន្តិសុខ នៃនាយកដ្ឋានសារៈមន្ទីរ
៦៤-លោក	ដឹក	យឹន	អនុប្រធានក្រុមសន្តិសុខ នៃនាយកដ្ឋានសារៈមន្ទីរ
៦៥-លោក	មុំ	ឆៃ	បុគ្គលិក សារមន្ទីរទួលស្លែង នៃនាយកដ្ឋានសារៈមន្ទីរ
៦៦-លោក	នឹម	សុន	អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានបេតិកភណ្ឌ
៦៧-លោកស្រី	យិន	រត្ននិន្ទី	អនុប្រធានការិយាល័យស្រាវជ្រាវ នៃនាយកដ្ឋានបេតិកភណ្ឌ
៦៨-លោកស្រី	អួង	ចាន់ធី	អនុប្រធានការិយាល័យរដ្ឋបាល នៃនាយកដ្ឋានបេតិកភណ្ឌ
៦៩-លោក	សេង	សោភ	មន្ត្រី នៃនាយកដ្ឋានបេតិកភណ្ឌ
៧០-លោក	ជឹម	សុគ្នា	បុគ្គលិកការិយាល័យរដ្ឋបាល នៃនាយកដ្ឋានសៀវភៅនិងការអាន
៧១-លោក	ម៉ម	តិណ្ណារ៉ា	អនុប្រធានការិ.បោះពុម្ពនិងគ្រប់គ្រង នៃនាយកដ្ឋានសៀវភៅ និងការអាន
៧២-លោក	ហេង	គីមអ៊ន់	បុគ្គលិកការិយាល័យកិច្ចការទូទៅ នៃនាយកដ្ឋានសៀវភៅ និងការអាន
៧៣-លោក	ពេជ្រ	ថាលី	អនុប្រធានការិ.តំកល់ទុកស្របច្បាប់ នៃនាយកដ្ឋានសៀវភៅ និងការអាន
៧៤-លោកស្រី	ថាច់	ធីតាព	បុគ្គលិកការិ.បោះពុម្ពនិងគ្រប់គ្រង នៃនាយកដ្ឋានសៀវភៅ និងការអាន
៧៥-លោក	ជា	អេង	អនុប្រធានការិ.គ្រប់គ្រង នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៧៦-លោកស្រី	តាត	សុផន	លេខាធិការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៧៧-លោកស្រី	យឹម	រដ្ឋា	ភ្នាក់ងាររដ្ឋបាល នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៧៨-លោក	រស់	សំរឿន	មន្ត្រីក្រមការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៧៩-លោក	សេង	សុផុន	មន្ត្រីក្រមការ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨០-លោក	ទុំ	សារ៉ែន	គ្រូបង្រៀនឧត្តម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨១-លោក	ចាន់	ឡៃហេង	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨២-លោកស្រី	រស់	នាង	ប្រធានការិយាល័យរដ្ឋបាល នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨៣-លោក	សំ	ស្រី	ប្រធានការិយាល័យសិក្សា នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨៤-លោក	កែវ	ម៉ាលីស	អនុប្រធានការិយាល័យ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨៥-លោកស្រី	ផន	ធូរ៉ែន	គ្រូបង្រៀន នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨៦-លោកស្រី	ឈឹម	សុខា	គ្រូបង្រៀន នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨៧-លោក	ញឹម	សិន	អនុរក្ស នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨៨-លោកស្រី	នួន	គន្ធរ	គ្រូបង្រៀន នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨៩-លោក	ស៊ុន	សារ៉ាត	គ្រូបង្រៀនឧត្តម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

៩០-លោក	ចាន់	សារិន	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩១-លោក	ហួត	ស៊ីថន	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩២-លោក	សៀង	ខូនលី	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩៣-លោក	សេក	សាធុន	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩៤-លោក	ឆោម	សិរីវុឌ្ឍ	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩៥-លោក	ប៊ូ	ឡេង	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩៦-លោក	ម៉ិន	សំបិន	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩៧-លោក	ប្រាក់	បូរ៉ា	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩៨-លោក	ជុំ	គង់	គ្រូបង្រៀនមធ្យម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៩៩-លោក	មួង	ចំន្ទាសនា	ប្រធានការិយាល័យស្ថិតិ នៃនាយកដ្ឋានសិក្សាស្រាវជ្រាវ និង តុល្យភាពការងារ
១០០-លោក	ឯក	ប៊ុនថា	ប្រធានការិ.បណ្តុះបណ្តាល នៃនាយកដ្ឋានបុគ្គលិក
១០១-លោក	គុជ	ទ៉ាន់នី	អនុប្រធានការិ.បៀវត្ស និងក្របខ័ណ្ឌ នៃនាយកដ្ឋានបុគ្គលិក
១០២-កញ្ញា	ឃ៉ីវ	ចន្ថន	អនុប្រធានការិ.រដ្ឋបាល នៃនាយកដ្ឋានបុគ្គលិក
១០៣-លោក	អ៊ុក	ឡៃ	ប្រធានការិ.ទំនាក់ទំនងវប្បធម៌បរទេស នៃនាយកដ្ឋានរដ្ឋបាលទូទៅ
